# ការសំភាសន៍របស់ ប៉ែន សារ៉េត

កៈ អ្នកដែរសំភាសន៍ ជាង ស៊ីអារ    ខៈ អ្នកដែរអោយគេសំភាសន៍ ប៉ែន សារ៉េត

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍នេះត្រូវបានរៀបចំដោយសាលាសកលវិទ្យាមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសាលាមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់នឹងបានដឹងពីប្រវត្តិដូនតានឹងឪពុកម្តាយចឹងហាសបង ចឹងនៅពេលដែរខ្ញុំសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍នេះទីក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសបង ចឹងនៅពេលដែរខ្ញុំសំភាសន៍បងហើយ តើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ បាទអត់អីទេ

កៈ បានណាបង បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍នេះត្រូវធ្វើនៅថ្ងៃទី24 ខែ1 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ នៅខ័ណ្ឌចំការមន រាជធានីភ្នំពេញចឹងហាសបង បាទបងចឹងសំរាប់បងឈ្មោះពេញរបស់បងមានឈ្មោះអីគេដែរបង?

ខៈ ឈ្មោះ ប៉ែន សារ៉េត

កៈ ឈ្មោះ ប៉ែន សារ៉េត ចុះមានឈ្មោះហៅក្រៅអត់បង?

ខៈ ឈ្មោះខ្ញុំឈ្មោះ រ៉េតនឹងហើយ

កៈ ឈ្មោះរ៉េតនឹងហោសបង ចុះកាលពីនៅក្មេងមាននរណាគេហៅឈ្មោះបងអីផ្សេងទៀតអត់បង?

ខៈ អត់មានទេមានតែឈ្មោះមួយនឹង

កៈ អូមានតែឈ្មោះមួយនឹងទេ ចុះបងសព្វថ្ងៃបងអាយុប៉ុន្មានដែរបង?

ខ៖ ខ្ញុំអាយុ36ឆ្នាំ

ក៖ អាយុ36ឆ្នាំណាបង ចុះបងកើតនៅថ្ងៃខែឆ្នាំណាបង?

ខ៖ នៅឆ្នាំ1982

ក៖ នៅឆ្នាំ1982ណាបង ចុះឆ្នាំច័ន្ទគតិបងឆ្នាំអីគេដែរបង?

ខ៖ ខ្ញុំឆ្នាំកុល

ក៖ ឆ្នាំកុលណាបង ចុះថ្ងៃខែបងមានដឹងថាថ្ងៃអី ខែអីអត់បង?

ខ៖ ចាំអត់បានទេ

ក៖ អូបង ចុះបងកើតនៅភូមិអីគេដែរបង?

ខ៖ ខ្ញុំនៅភូមិចុងឃ្នាស

ក៖ ភូមិចុងឃ្នាស ស្រុកអីគេដែរបង?

ខ៖ ស្រុកសៀមរាប ខេត្តសៀមរាប

ក៖ អូចុះឃុំអីគេដែរបង?

ខ៖ ឃុំចុងឃ្នាសដែរនឹង

ក៖ ឈ្មោះឃុំចុងឃ្នាសចឹងតែម្តងហោសបង ចុះបងមានបងប្អូនប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានបងប្អូន3នាក់

ក៖ ចុះមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានស្រី1នាក់ ប្រុស2នាក់

ក៖ ចុះបងប្អូនរបស់បងតើបងមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖ ខ្ញុំចងចាំតា

ក៖ ចុះគាត់មានឈ្មោះអីគេដែរបង?

ខ៖ ឈ្មោះ រ៉ុង

ក៖ នឹងបងទី1ណាបង?

ខ. បងទី1

ក៖ ចុះបងទី2ដែរបង?

ខ៖ ទី2ឈ្មោះ សម្បត្តិ

ក៖ ចុះទី3វិញបង?

ខ៖ ទី3ខ្ញុំនឹងហើយ

ក៖ ចុះបងធ្លាប់មានចងចាំសាច់រឿងអី រឺមួយក៏អនុស្សាវរីយ៍ជាមួយបងប្អូនរបស់បងទេ?

ខ៖ មិនសូវចាំដែរនឹងហាស

ក៖ ដូចជាបងធ្លាប់លេងអីជាមួយគ្នា ដូចជាលេងឡឹកបាយឡអីជាមួយគ្នា
រឺមួយក៏លេងបិទពួន រឺមួយលេងគប់កំប៉ុង គប់ឈូសអីចឹងហាស?

ខ៖ កាលណុងបានថាជួបជុំជាមួយគ្នាយូរហាស ហើយខ្ញុំកំព្រាឪពុកម្តាយទៅ
ដូចថាខ្ញុំបែកបាក់កំលាំងគ្នាចេញរកស៊ីរៀងៗខ្លួនចឹងទៅ

ក៖ បាទបងចឹងយើងអត់សូវបានជួបគ្នាទេណា
ប៉ុន្តែបងធ្លាប់ទៅធ្វើស្រែអីជាមួយគ្នាដែរទេបង?

ខ៖ អត់អត់ដែរធ្លាប់ទេ

ក៖ បងអត់មានស្រែធ្វើទេណាបង?

ខ៖ អត់នៅខាងខ្ញុំនឹងខ្ញុំរកតែត្រីនឹង

ក៖ អូរកត្រី ចុះចំការក៏អត់មានដែរណាបង?

ខ៖ ចំការក៏អត់មានដែរ

ក៖ ចុះបងគិតថាបងធ្លាប់ទៅរកត្រី រឺមួយក៏ទៅរកអីជាមួយបងប្អូនរបស់បង
រឺមួយក៏លេងបិទពួន រឺក៏លេងអីមួយដែរបងគិតថាបងចាំហាស?

ខ៖ មានដែរមាន

កៈ ចាំថាលេងអីជាមួយពួកគាត់ដែរបង?

ខៈ តែវាយយូរដែរហើយនឹង

កៈ ប៉ុន្តែធ្វើអីគេដែរបង?

ខៈ ប្រវត្តិមានច្រើនណាស់ថាទៅរកស៊ីទៅរកអីជាមួយគ្នាចឹងទៅណា
មុជទឹកប្រលែងគ្នាលេងអីចឹងទៅណាស់

កៈ បាទបងចង់និយាយចឹងហាសបង?

ខៈ មានប្រវត្តិនឹង

កៈ ចុះកាលពីនៅក្មេងបងចូលចិត្តលេងអីជាមួយបងប្អូនរបស់បងដែរ?

ខៈ ខ្ញុំនិយាយរួមទៅខ្ញុំនៅខាងស្រុកទឹក ខ្ញុំចូលចិត្តតែមុជទឹកប្រលែងគ្នាលេងចឹងទៅ

កៈ ប៉ុន្តែបងនឹងបងប្អូនរបស់បងចេះហែលទឹកទាំងអស់គ្នា?

ខៈ ចេះហែលទឹកទាំងអស់គ្នា

កៈ ចឹងបងភាគច្រើនលេងទឹកប្រលែងគ្នាទៅ?

ខៈ បាទលេងទឹក លេងបិទពួនទៅណាស់

កៈ អូចុះមួយថ្ងៃបងលេងប៉ុន្មានដងដែរបង?

ខៈ មួយថ្ងៃជួនកាលយើងនៅក្មេងចឹងទៅ
និយាយរួមទៅវាក្មេងវាសឹងតែរាល់ថ្ងៃនឹងមួយថ្ងៃ2-3ដងអីចឹងទៅណាពេលដែរទំនេរ

កៈ ចុះបងប្អូនរបស់បងសព្វថ្ងៃគាត់រស់នៅណាដែរបង ដូចជាបងធំរបស់បងហាស?

ខៈ គាត់នៅខាងសៀមរាបទាំងអស់នឹង

កៈ ចុះគាត់ធ្វើអីគេដែរបង?

ខៈ ឥឡូវគាត់រកត្រី

កៈ ចុះបងបន្ទាប់បងធំវិញបង?

ខ៖ បងបន្ទាប់នឹងឥឡូវនឹងគាត់នៅផ្ទះដែរនឹង ចំណែកប្ដីរបស់គាត់រកត្រីដែរ

ក៖ ចុះក្រុមគ្រួសាររបស់គាត់ទៅរកត្រីដែរ យកទៅលក់នៅផ្សារមែនបង?

ខ៖ បាទយកទៅលក់នៅផ្សារ

ក៖ យកទៅលក់នៅផ្សារណាដែរបង ?

ខ៖ លក់នៅផ្សារជិតផ្ទះនឹង

ក៖ ផ្សារដើមក្រលាញ់មែនបង?

ខ៖ ផ្សារបឹងក្រោមនឹង

ក៖ ផ្សារបឹងក្រោមនឹងនៅណាវិញបង នៅជិតខេត្តរឺមួយក៏នៅឆ្ងាយពីខេត្តដែរបង?

ខ៖ នៅវាឆ្ងាយដែរនឹង

ក៖ ចឹងនៅតាមស្រុកហោសបង?

ខ៖ នៅប្រហែលជា7-8គីឡូដែរនឹង

ក៖ ដូចជានៅម្ដុំខាងដំដែកមែនទេបង?

ខ៖ អត់ទេទៅណោះទៅ យើងចុះពីខេត្តទៅទៀតគេហៅថាភ្នំក្រោម

ក៖ ភ្នំក្រោមហោសបង?

ខ៖ បាទខ្ញុំនៅនឹងអែង

ក៖ អូស្គាល់តាបង

ខ៖ ខ្ញុំនៅជិតនឹងអែង

ក៖ អូនៅជិតភ្នំក្រោមនឹងអូចឹងនៅជាប់ខេត្តសៀមរាបដែរនឹងបង?

ខ៖ បាទនៅជិតនឹងដែរនឹង

ក៖ ដោយសារតែខ្ញុំទៅលេងភ្នំគូលេន ហើយខ្ញុំជិះទៅដល់ភ្នំក្រោមច្រើនដែរនឹង ខ្ញុំធ្លាប់បានទៅនៅណុងបាន3-4ខែចឹងខ្ញុំស្គាល់នៅណុងច្រើនដែរនឹង បាទបងសំរាប់ម្ដាយរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ គាត់ឈ្មោះ សំ

ក៖ ចុះគាត់អាយុប៉ុន្មានដែរសព្វថ្ងៃនឹង?

ខ៖ ម៉ែគាត់ស្លាប់បាត់យូរដែរហើយនឹង គាត់បានស្លាប់តាំងពីអាយុ42ឆ្នាំមកហើយ កាលណុងខ្ញុំនៅអាយុប្រហែលជា2ឆ្នាំ

ក៖ ប៉ុន្តែគាត់នឹង

ខ៖ ហើយមកដល់ឥឡូវនឹងខ្ញុំអាយុ36ឆ្នាំគាត់ស្លាប់34ឆ្នាំហើយនឹង

ក៖ គាត់ស្លាប់អស់រយះពេល34ឆ្នាំ ចឹងពេលដែរគាត់ស្លាប់នឹងអាយុ42ឆ្នាំ ចឹងគាត់ចូលខ្ទង់76ឆ្នាំឥឡូវគាត់76ឆ្នាំហើយបង

ខ៖ នឹងហើយគាត់ប្រហែលជាប៉ុណ្ណឹង

ក៖ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាបងមានដឹងទេបង?

ខ៖ ខ្ញុំចាំអត់បានដែរនឹង

ក៖ ចឹងសំរាប់គាត់គាត់អាយុ76ឆ្នាំ

ខ៖ គាត់ស្លាប់នឹងខ្ញុំនៅតូចពេក

ក៖ ចឹងគាត់កើតនៅឆ្នាំ1942បង បាទបងចុះគាត់ឆ្នាំច័ន្ទគតិឆ្នាំជូត ឆ្លូវ ខាល ថោះគាត់ឆ្នាំអីគេបងមានដឹងទេបង?

ខ៖ ខ្ញុំអត់ដឹងដែរនឹង ពីព្រោះអីខ្ញុំនៅតូចហោសចឹងខ្ញុំអត់ដឹងដែរនឹង

ក៖ អូចុះគាត់កើតនៅណាបងមានចងចាំទេបង?

ខ៖ គាត់កើតនៅស្រុកណុង

ក៖ អូគាត់កើតនៅស្រុកណុងហោសបង?

ខ៖ បាទៗគាត់កើតនៅស្រុកភូមិណុងតែម្តងនឹង

ក៖ ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ ឪពុកឈ្មោះ រី

ក៖ ប៉ុន្តែសព្វថ្ងៃគាត់នៅរស់តាហីបង?

ខ៖ សព្វថ្ងៃគាត់នៅរស់តែគាត់បានប្រពន្ធទៀតហើយ

ក៖ ប៉ុន្តែគាត់អាយុប៉ុន្មានដែរបងមានដឹងទេ?

ខ៖ ឥឡូវគាត់អាយុចិតជាងហើយតែមិនដឹងជាអាយុចិតប៉ុន្មានដែរទេមិនដឹងដែរ ដូចជាខ្ញុំមិនសូវជាចងចាំទេ

ក៖ ចឹងមានន័យថាគាត់កើតនឹងប្រហែលជាឆ្នាំ1940ជាងដែរណាបង?

ខ៖ គាត់កើតប្រហែលនឹងពីព្រោះអីគាត់បងម្តាយរបស់ខ្ញុំប្រហែលឆ្នាំ3ឆ្នាំ

ក៖ អូគាត់បង3ឆ្នាំចឹងមានន័យថាគាត់កើតនៅឆ្នាំ1937-1938ហើយចឹង ចុះគាត់កើតនៅណាដែរឪពុករបស់បងហាស?

ខ៖ គាត់ដូចថានៅភូមិចំណោម រោងគោ

ក៖ ភូមិចំណោមណាបង ចុះឪពុករបស់បងគាត់ធ្វើអីសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ អូឥឡូវគាត់ពិការគាត់ធ្វើអីអត់កើតទេ

ក៖ អីប៉ុន្តែកាលពីមុនគាត់ធ្វើអីគេដែរបង?

ខ៖ កាលពីមុនគាត់ធ្វើចំការ

ក៖ អូបាទចុះគាត់មានធ្លាប់លក់ដូរអីអត់បង?

ខ៖ អត់ទេ

ក៖ អត់ទេណាបងចុះគាត់ជាមនុស្សយ៉ាងម៉េចដែរបងគាត់ស្លូតរឺមួយក៏កាចដែរបង?

ខ៖ ឥឡូវគាត់ស្គមគាត់មើលតែចៅនឹង

ក៖ អូប៉ុន្តែគាត់ស្លូតរឺមួយក៏គាត់កាចដែរបង?

ខ៖ គាត់ស្លូតទេ

ក៖ អូគាត់ស្លូតហោសបង ចុះម្ដាយរបស់បងគាត់ធ្វើអីសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ កាលណុងគាត់ទៅរកត្រីនៅទន្លេសាបនឹងដែរ

ក៖ អូប៉ុន្តែគាត់ស្លូតរឺមួយក៏កាចដែរបង?

ខ៖ គាត់ក៏ស្លូដែរនឹង

ក៖ ចុះម្ដាយឪពុករបស់ពេលដែរបងនៅជាមួយគាត់ដូចជាបងធ្លាប់មានសាច់រឿងអីកាលពីបងនៅជាមួយគាត់ដែរទេបង ដែរបងគិតថាចាំអត់ភ្លេចហាសបង?

ខ៖ តាមពិតទៅខ្ញុំនៅតូចដែរនឹងខ្ញុំមិនសូវជាចាំប៉ុន្មានដែរទេ បើខ្ញុំចាំខ្ញុំចាំតែការរកស៊ីអីនឹងទេគាត់យកកូនថៅទៅក្នុងព្រៃអីមានអានឹង ទៅដេកទៅរកស៊ីនៅក្នុងព្រៃអីចឹងអានឹងមានតា អានឹងខ្ញុំអាចចាំបានប៉ុន្តែអ្វីៗអ្វីផ្សេងខ្ញុំអត់ចងចាំទេ ខ្ញុំនៅក្មេងខ្ចីពេក

ក៖ អូចឹងម្ដាយរបស់បងគាត់មិនដែរប្រាប់អីទៅបងទេណាបងដោយសារតែបងនៅតូចពេកណាបង?

ខ៖ បាទដោយសារតែខ្ញុំនៅតូចពេកនឹង

ក៖ ចុះឪពុករបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិគាត់អត់បង?

ខ៖ ឪពុករបស់ខ្ញុំគាត់បានចាកចេញពីខ្ញុំនឹងមុនម្ដាយរបស់ខ្ញុំស្លាប់នឹងយូរដែរនឹង កាលណុងម៉ែរបស់ខ្ញុំនឹងមេម៉ាហើយដល់ពេលណុងទៅខ្ញុំបានអាយុ2ខួបគាត់ក៏បានស្លាប់បាត់ទៅ

ក៖ ចុះបងនៅជាមួយនរណាគេទៅបង?

ខ៖ ខ្ញុំនៅជាមួយនឹងជីដូន

កៈ អូចឹងបងប្អូនរបស់បងទាំងអស់នៅជាមួយជីដូន?

ខៈ ទាំងអស់គ្នានឹង

កៈ ប៉ុន្តែយាយតាខាងណាដែរបងយាយតាខាងម្តាយមែនទេបង?

ខៈ នៅខាងម្តាយនឹង

កៈ ចុះយាយតាខាងឪពុកបងមានចងចាំឈ្មោះគាត់ទេបង?

ខៈ ចាំតាខាងឪពុក

កៈ គាត់ឈ្មោះអីគេដែរបង?

ខៈ តាគាត់ឈ្មោះ ទែន

កៈ ចុះយាយវិញបង?

ខៈ យាយអត់ចងចាំទេ

កៈ ចុះគាត់កើតនៅឆ្នាំណា ហើយគាត់នៅណាបងចាំអត់បង?

ខៈ ខ្ញុំអត់ដឹងដែរដឹងតែស្រុកកំណើតរបស់គាត់នៅណុងតែម្តងនៅក្រោលគោនឹង

កៈ ចុះយាយតាខាងម្តាយបងស្គាល់ឈ្មោះគាត់ទេបង?

ខៈ ខ្ញុំស្គាល់តា

កៈ ចុះគាត់មានឈ្មោះអីគេដែរបង?

ខៈ គាត់ឈ្មោះឡម

កៈ គាត់មានឈ្មោះ ឡម ចុះតាវិញបង?

ខៈ តាគាត់ឈ្មោះ គាន់

កៈ ចុះគាត់កើតនៅឆ្នាំណាបងមានចងចាំទេបង?

ខៈ ខ្ញុំអត់ចាំដែរបីព្រោះអីគាត់ស្លាប់តាំងពីសម័យពលពតមកហើយនឹង

កៈ អូបាទបង ចុះយាយតាគាត់បានកើតនៅណាបងមានដឹងអត់បង?

ខ៖ យាយតាគាត់កើតនៅខាងនឹងនៅស្រុកភូមិខ្ញុំនឹងនៅភូមិចុងឃ្នាសនឹង

ក៖ ចុះឪពុកម្ដាយរបស់បងគាត់មានធ្លាប់ពីប្រវត្តិជីដូនជីតាទៅបងទេ
ថាជីដូនជីតាកាលពីគាត់នៅក្មេងៗគាត់ធ្លាប់បានធ្វើអីគេចឹងហាស?

ខ៖ កាលណុងដូចជាអត់មានធ្វើអីទេ កាលណុងនៅសម័យពលពតនឹង
បាទដូចថាធ្វើការបំរើគេចឹងហាសធ្វើស្រែធ្វើចំការចឹងហាស ដូចថាធ្វើជាពលករចឹងហាស

ក៖ បាទបងមកនឹងមកលេងបងវណ្ណ?

ខ៖ ខ្ញុំមកនឹងមកធ្វើការងារ

ក៖ បងមកធ្វើការងារហោស ចុះបងមកភ្នំពេញនឹងបានប៉ុន្មានដែរហើយបង?

ខ៖ ខ្ញុំទើបតែមកដល់នឹង

ក៖ អូចឹងបងទើបតែមកដល់ហោសបង?

ខ៖ នឹងហើយទើបតែមកដល់មិញនឹងហាស

ក៖ ចុះសំរាប់បងនៅខេត្តសៀមរាបនឹងយូរនៅបង?

ខ៖ ស្រុកកំណើតខ្ញុំនៅនឹងតែម្ដង

ក៖ ចឹងមានន័យថាប្រហែលជា30ឆ្នាំជាងហើយមែនទេ ដូចជា36-37ឆ្នាំហើយបង?

ខ៖ បាទយូរដែរហើយ

ក៖ ចឹងដូចជាបងមានសាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសអត់បង
បងប្អូនរឺមួយក៏សាច់ញ្ញាតិអីផ្សេងអីអត់បង?

ខ៖ អត់មានដែរ

ក៖ នៅថៃ នៅវៀតណាមអីមានទេបង?

ខ៖ អត់មានទេ

ក៖ អត់មានទេណាបង ចុះភរិយារបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ គាត់ឈ្មោះ លន់

កៈ ឈ្មោះ លន់ ចុះបងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរបងមានចាំទេ?

ខៈ មិនដឹងថាថ្ងៃប៉ុន្មានទេតែ2ឆ្នាំហើយ អត់ទាន់បាន2ឆ្នាំទេ

កៈ អត់តាន់បាន2ឆ្នាំទេណាបង?

ខៈ ហាសចូល2ឆ្នាំហើយ

កៈ
ចុះបងជាអ្នករៀបចំអាពាហ៍ពិពាហ៍ដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយរបស់បងជាអ្នករៀបចំអោយដែរបង?

ខៈ
ឪពុកម្តាយគាត់ជាអ្នករៀបចំអោយនឹងខាងស្រីដែរបងមកបងប្អូនមកជាអ្នករៀបចំអោយអ្នកនៅខាងស្រុកស្វាយរៀង

កៈ ចុះដូចជាបងមានជាចំនូនអោយគាត់ទេបង ដូចជាបណ្ណាការហាសបង?

ខៈ មានដែរតែតិចតួចនឹង

កៈ មានតិចតួចហោសបង
ចុះបងចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរបង?

ខៈ មិនសូវចេះដែរនឹង

កៈ ប៉ុន្តែបងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខៈ ខ្ញុំរៀនបានថ្នាក់ទី3នឹង

កៈ រៀនបានថ្នាក់ទី3ចុះរៀនបឋមសិក្សានៅណាវិញបង?

ខៈ រៀននៅខាងស្រុកខ្ញុំនឹង នៅសៀមរាប

កៈ ឈ្មោះអីគេដែរបងអាចប្រាប់ឈ្មោះសាលាបានទេបង?

ខៈ ឈ្មោះសាលាបឋមសិក្សាចុងឃ្នាស

កៈ នៅចុងឃ្នាស ចុះនៅភូមិអីបង?

ខ៖ នៅភូមិចុងឃ្នាស ឃុំចុងឃ្នាស ស្រុកសៀមរាប ខេត្តសៀមរាប

ក៖ អូនៅខេត្តសៀមរាបចឹងតែម្ដងហោសបង ចុះបងមានដែរប្ដូរសាលាអត់បង?

ខ៖ អត់មានទេ

ក៖ បងរៀនតែនៅសាលានឹងមួយទេ?

ខ៖  អត់ខ្ញុំរៀនតែនៅសាលាស្រុកនឹងមួយនឹង

ក៖ ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរអត់បង?

ខ៖ អត់មានទេ

ក៖ ចឹងបងចេះតែខ្មែរទេណាបង?

ខ៖ ចេះតែខ្មែរមួយនឹង

ក៖ ចឹងភាសាវៀតណាម ថៃអីបងអត់ចេះដែរណាបង
នៅសៀមរាបបងសុំតែចេះថៃហើយបង?

ខ៖ អត់អត់ចេះទេ

ក៖ អូបាទចុះបងមានមិត្តណាដែរធំធាត់មកជាមួយគ្នាអត់បង?

ខ៖ មានដែរតែបែកបាក់គ្នាធំៗរៀងៗខ្លួនអស់ហើយនឹង

ក៖
ចុះបងអាចរៀបរាបប្រាប់ឈ្មោះពួកគាត់ខ្លះៗបានទេបងថាគាត់មានឈ្មោះអីគេខ្លះមិត្តភក្តិរបស់បងហាសបង?

ខ៖ ខ្ញុំភ្លេចអស់ហើយ

ក៖ ដូចជាម្នាក់ទៅពីរនាក់ក៏បានដែរបង ដែរបងគិតថារៀនជាមួយគ្នាអី
ហើយបងធ្លាប់ដើរលេងជាមួយគ្នាអីចឹងហាសបង?

ខ៖ មានឈ្មោះ ,ដែន ឈ្មោះ, ខាល ឈ្មោះ នះ, ឈ្មោះ វី ខ្ញុំចាំអត់សូវបានទេ

ក៖ អូអត់អីទេបង?

ខ៖ វាយូរដែរហើយនឹង

ក៖ ចុះបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់អីពីមុនហាស?

ខ៖ មានដូចថារៀនសាលាជាមួយគ្នាចឹង
ដូចថានៅស្រុកខ្ញុំចឹងអត់មានកង់អីជិះទេយើងដើរទៅរៀនទៅ ពីព្រោះអីសាលានៅក្នុងទឹក ហើយពេលដែរយើងទៅរៀនចឹងយើងមានទូកមួយសំរាបអ៊ុំចំលងគ្នាទៅវិញទៅមករំលងពីផ្ទះមួយទៅផ្ទះមួយយកគ្នាមករៀនសាលានៅទឹក

ក៖ ចុះបងធ្លាប់ទៅធ្វើការងារនៅវាលស្រែរឺមួយក៏ចំការអីអត់បង?

ខ៖ អត់ដែលដែរនឹងឥឡូវខ្ញុំធ្វើតែសំណង់នឹង

ក៖ អូបាទបង ចុះបងមានធ្លាប់អាជីវកម្មអីនៅក្នុងក្រុមគ្រួសារអីអត់បង លក់ដូរអី?

ខ៖ ខ្ញុំមាន

ក៖ ចុះចិញ្ចឹមសត្វអីបងមានអត់ដូចជាចិញ្ចឹមមាន់ ចិញ្ចឹមទា គោ ក្របីអីចឹងហាស?

ខ៖ អត់មានទេ

ក៖ អទ់ដែរមានទេណាបង
ចុះបងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះបងគិតថាបងធ្លាប់ធ្វើការងារអីគេខ្លះដែរបង?

ខ៖ ខ្ញុំមិនដែរបានធ្វើអីទេខ្ញុំធ្វើតែសំណង់នឹង

ក៖ អូធ្វើតែសំណង់ទេណាបង?

ខ៖ ធ្វើសំណង់ហើយនឹងធ្វើដែកអីតិចតួចនឹង

ក៖ អូបាទបង ចុះកាលពីក្មេងក៏បងធ្វើតែអានឹងដែរណាបង
ប៉ុន្តែកាលពីក្មេងបងធ្លាប់ទៅរកត្រី រកអីដែរមែនទេបង?

ខ៖ រកពីមុននឹងរកត្រីដែរ

ក៖ រកលក្ខណះទៅលក់រឺយ៉ាងម៉េចដែរបង?

ខ៖ រកទៅលក់នឹងតែយើងអត់បានទៅក៏យើងរកការងារធ្វើទៅ
យើងភ្លេចការរកត្រីទៅយើងមកចាប់អាជីពធ្វើសំណង់វិញ

ក៖ អូបាទបង
ចុះតាំងពីក្មេងរហូតមកដល់ពេលនេះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្តូរអីគេខ្លះដែរបង?

ខ៖ តាមពិតទៅវាអត់មានការផ្លាស់ប្តូរអីទេនៅតែដដែលនឹង

ក៖ ប៉ុន្តែបងគិតថាពីមុនបងមិនចេះរកត្រីតែឥឡូវបងចេះរក
ហើយការងារសំណង់ពីមុនបងមិនចេះទេតែឥឡូវបងចេះស្ទាត់

ខ៖ នឹងផ្លាស់ប្តូរចឹង

ក៖ បងគិតថាពីមុនបងរកលុយអត់បានតែឥឡូវបងរកលុយបានចឹងហាសបង
បងអាចប្រាប់ការផ្លាស់ប្តូរអីតិចទៀតបានទេបង?

ខ៖ ពីដំបូងខ្ញុំដូចថាខ្ញុំមិនសូវជំនាញដូចនឹងមែនតែឥឡូវមានការផ្លាស់ប្តូរតិចដែរនឹង
ពីមុនខ្ញុំនៅកម្មករតែឥឡូវខ្ញុំឡើងជាងដែរនឹង

ក. អូឥឡូវបងឡើងជាងណាបង?

ខ៖ ហើយឥឡូវនឹងក៏វាឡើងកំរៃបន្តិចដែរនឹងហាស

ក៖ កម្មករគេអោយប៉ុន្មានដែរបង?

ខ៖ កាលណុងកម្មករកាលណុងខ្ញុំធ្វើយូរដែរហើយណា

ក៖ គេអោយមួយថ្ងៃប៉ុន្មានដែរបង?

ខ៖ កម្មករគេអោយមួយថ្ងៃ5000៛

ក៖ ប៉ុន្តែខ្ញុំលឺគេថាកម្មករមួយថ្ងៃគេអោយច្រើនដែរហោសបង?

ខ៖ បាទកម្មករគេអោយមួយថ្ងៃ25000៛-30000៛ ហើយជាងមួយថ្ងៃបាន10$បង

ក៖ ឥឡូវហោសបង ប៉ុន្តែឥឡូវនឹងបងរកការងារអត់ទាន់បានធ្វើទេ?

ខ៖ បាទនៅទេ

ក៖ បងកំពុងតែស្វែងរកការងារនៅភ្នំពេញណាបង?

ខ៖ ខ្ញុំទើបតែមកនឹង

ក៖ អូបាទបងចុះបងចូលចិត្តពិសារម្ហូបអីគេដែរបង?

ខ៖ ធម្មតាដែរនឹងអ្នកស្រែដូចជាស្ងោរ នឹងស្លម្ជូរអីនឹង

ក៖ ចុះសម្លការី កកូរ ឆា ចៀន អីនឹងបងចូលចិត្តអត់បង?

ខ៖ ចូលចិត្តដែរ តែនិយាយរួមទៅយើងអត់សូវមានលទ្ធភាពដែរនឹង

ក៖
ចុះល្បែងប្រជាប្រិយ៍ដែរបងគិតថាបងចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖ មានខែចូលឆ្នាំអី ទៅវត្តអីលេងចោលឈូង ទាញព្រាតអីនឹងហាស

ក៖ ចុះលាក់កន្សែងអី បោះអង្គុញអីបងចូលចិត្តទេបង?

ខ៖ បាទចូលចិត្តទាំងអស់នឹងហាស

ក៖ លក្ខណះថាពង្រត់កូនក្រមុំអីបងចូលចិត្តអត់បង?

ខ៖ បាទចូលចិត្តដែរ

ក៖ បាទខ្ញុំក៏ចូលចិត្តដែរនឹង
ចុះបតងគិតថាបងមានចងចាំបទចំរៀងណាដែរបងគិតថាបានរៀនច្រៀងតាំងពីក្មេងរហូតមកដល់ពេលនេះទេបង?

ខ៖ និយាយរួមទៅខ្ញុំមិនដែរថានឹកឃើញផងអារឿងចឹងអីនឹង

ក៖ ប៉ុន្តែបងចេះច្រៀងទេបង?

ខ៖ អត់ទេ

ក៖ ប៉ុន្តែបងចូលចិត្តបទចំរៀងទេបង?

ខ៖ ខ្ញុំចូលចិត្តដែរស្តាប់ដែរ ដូចជាបទណាយ៉ាន់ណោតអីបន្តិចបន្តួចដែរនឹង

ក៖ ប៉ុន្តែលក្ខណៈបទសម័យរឺមួយក៏បទបុរាណដែរបង?

ខ៖ បទបុរាណ

ក៖ ប៉ុន្តែបទសម័យបងមិនសូវចូលចិត្តទេ?

ខ៖ អត់ទេ

ក៖
អូបាទបងចុះមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់បងចេះលេងឧបករណ៍ភ្លេងទេបង?

ខ៖ អត់មានដែរពីព្រោះអីគ្រួសាររបស់ខ្ញុំមានតែ3នាក់សុទ្ធតែអ្នករកស៊ីនឹង

ក៖ ចុះបងប្អូនជីដូនមួយរឺមួយក៏អ៊ុំមីង ពូ មា អីផ្សេងៗមាននរណាគេចេះលេងទេបង?

ខ៖ អត់មានដែរនឹង

ក៖ ចឹងអត់មាននរណាគេចេះលេងឧបករណ៍ភ្លេងអីទេណាបង?

ខ៖ បាទអត់មានទេ

ក៖ បាទបង
ចុះផ្ទះរបស់បងមានលក្ខណៈបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង
?

ខ៖ ផ្ទះរបស់ខ្ញុំតូច

ក៖ អូតូចណាបង ចុះឥឡូវនឹង?

ខ៖ ឥឡូវនឹងនៅតែប៉ុនដដែរនឹង

ក៖ ប៉ុន្តែកាលពីផ្ទះរបស់បងធ្វើនឹងនរណាគេជាអ្នកធ្វើ ដូចជាបងរឺមួយក៏ឪពុករបស់បង
រឺនរណាគេជាអ្នកធ្វើដែរបង?

ខ៖ បងប្អូនអីនឹងយើងអត់លុយខ្វះខាតអីនឹង យើងចូលលុយគ្នាធ្វើទៅណាដើម្បីនៅ

ក៖ ប៉ុន្តែយើងជួលគេធ្វើមែនទេបង?

ខ៖ យើងធ្វើដោយខ្លួនអែង

ក៖ អូធ្វើខ្លួនអែងហោស អូបងចេះធ្វើផ្ទះហោសបង?

ខ៖ បាទចេះតា

ក៖ ប៉ុន្តែនរណាគេជាអ្នកបង្រៀនបងដែរ?

ខ៖ ខ្ញុំដើរធ្វើការជាមួយជាងទៅ ខ្ញុំចេះធ្វើតាមគេយើងមើលគេទៅយើងចេះខ្លួនយើង

ក៖
បងគិតថាសងផ្ទះរបស់បងនឹងគេប្រើឧបករណ៍អីគេខ្លះសំរាប់សាងសងផ្ទះរបស់បងដែរបង?

ខ៖ វែឈើ វែឈើប្រកស្លឹក

ក៖ ប៉ុន្តែមានឧបករណ៍អីសំរាប់ដុំអីចឹងហាស?

ខ៖ មានដូចជាញញួរ នឹងពូថៅ នឹងរណាសំរាប់យើងអាចឹងទៅ

ក៖ ដូជាមានដែកឈូស មានរលាកមានអីផ្សេងទៀតអត់បង?

ខ៖ អត់មានទេពីព្រោះអីផ្ទះរបសយើងវាតូចដែរវាល្មមរស់នៅ

ក៖ អូបាទបង ហើយនឹងមានដែកជើងជ្រូកហាសបងដែកគាស់
សំរាប់គាស់ដែកគោហាសបង?

ខ៖ បាទមានដែកគាស់ ញញួរ ពូថៅ នឹងរណាដែរ

ក៖ ចុះបងគិតថាមានជំនាញអីដែរបងគិតថាបងចេះស្ទាត់ទេបង?

ខ៖ ខ្ញុំមានតែសំណង់នឹងមួយ

ក៖ ជំនាញខាងធ្វើសំណង់នោះបង
ចុះបងគិតថាបងមានជំនាញអីដែរបងគិតថាម្តាយឪពុករបស់បងគាត់បានបង្រៀនទេបង?

ខ៖ មានដូចថាគាត់ថា និយាយរួមទៅពេលដែរខ្ញុំធំឡើងខ្ញុំចេះអែងនឹង
ឃើញគាត់ពីដើមមកឃើញគាត់រៀនបូករៀនអីចឹង ដល់ពេលចឹងយើងចេះខ្លួនយើង

ក៖ ចុះវេញវល្លិ៍ កូរស្ក ធ្វើផ្តៅ ធ្វើកន្ទេលបងចេះទេបង?

ខ៖ អត់ចេះទេ

ក៖ អតចេះទេណាបង ចុះបងអាចប្រាប់ខ្ញុំបានទេពីពេលដែរបងលំបាក
ថាពេលណាដែរបងលំបាកអីចឹងហាសបង?

ខ៖ ពេលដែរខ្ញុំលំបាក
និយាយរួមទៅវាទូទៅទៅហើយការលំបាកអត់មានពេលណាដែរខ្ញុំបានស្រួលទេលំបាករហូតនឹង

ក៖ ចុះនៅពេលដែរបងនៅជាមួយក្រុមគ្រួសារបងលំបាកអីគេខ្លះ
ហើយបងមានការពិបាកអីគេដែរចឹងហាសបង?

ខ៖ លំបាកអី លំបាកតែការងារយើងធ្វើនឹង
លំបាកតែការងារយើងធ្វើចិញ្ចឹមជីវិតរាល់តែថ្ងៃនឹងតែវាធម្មតាយើងខ្សត់ខ្សោយចឹង
យើងខានធ្វើការងារអោយគេមួយថ្ងៃទៅពីរថ្ងៃចឹងយើងអត់មានអីហូបចឹងហាស

ក៖ ចុះនៅពេលដែរបងមានក្រុមគ្រួសារបងគិតថាបងមានការលំបាកអីគេដែរបង?

ខ៖ និយាយរួមទៅដូចតែគ្នានឹង

ក៖ ត្រូវការចិញ្ចឹមគ្រួសារ?

ខ៖ ចឹងហើយដូចថាខ្ញុំនិយាយចឹង
ដូចថាខ្ញុំលំបាកនឹងការងារដើម្បីជីវភាពនៅក្នុងគ្រួសារយើងនឹង
បើយើងខានធ្វើការងារមួយថ្ងៃចឹងគ្រួសាររបស់យើងអត់មានអីហូបដែរនឹង
លក្ខណះថាយើងរកមួយថ្ងៃសំរាប់មួយថ្ងៃចឹងហាស

ក៖ បាទបងចុះដូចជាបងឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរបង?

ខ៖ ខ្ញុំច្រើនណាស់ខ្ញុំ

ក៖ ដូចជាបងឆ្លងកាត់វាយ៉ាងម៉េចដែរ នឹងបងជំនះវាដោយយ៉ាងម៉េចដែរ
ដើម្បីបងអាចឆ្លងកាត់ការលំាបាកនឹងបានហាស បងអាចប្រាប់ខ្ញុំបន្តិចបានទេ?

ខ៖ ចឹងបានខ្ញុំខំតស៊ូទោះបីខ្ញុំនឿយហត់ប៉ុណ្ណាក៏ដោយខ្ញុំមិនរុញរា ហើយក៏ខ្ញុំមិនថយដែរនឹងពីព្រោះអីខ្ញុំគិតថាបើខ្ញុំរុណរា ហើយខ្ញុំថយចឹងគ្រួសាររបស់ខ្ញុំអត់មានអីហូបចុកទេ ពីព្រោះអីជីវភាពខ្ញុំខ្សត់ក្រខ្សោយចឹងដែរនឹង

ក៖ បាទបង ចុះបងគិតថាពេលណាដែរបងសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់បងហាសបង?

ខ៖ មានពេលសប្បាយម្តងមួយយាមដែរ ខែបុណ្យទានចឹងយើងជួបជុំបងប្អូនរបស់យើងចឹងយើងមានពេលដែរសប្បាយនឹងមិនមែន ថាយើងមានទុករហូតទេ

ក៖ ចុះពេលដែរបងរៀបការបងគិតថាបងសប្បាយទេ?

ខ៖ ពេលណុងសប្បាយខ្លាំងមែនទែនតែម្តងនឹង

ក៖ ពេលខ្លះក៏ហត់ខ្លាំងដែរណបងពេលការនឹង

ខ៖ នឹងហើយត្រូវហើយ

ក៖ ចុះបងគិតថាបងធ្លាប់មានក្តីស្រម៉ៃតាំងពីក្មេងរហូតមកដល់ពេលនេះទេ បងចង់ធ្វើអីមួយពេលដែរបងធំឡើងអីចឹងហាស?

ខ៖ មានតា

ក៖ ចង់ធ្វើអីគេដែរបង?

ខ៖ គិតថាចង់រកមុខរបរមួយអីដែរថាអោយស្រួលដែរ មិនសូវពិបាកកំលាំងយើងអោយមានលុយសល់

ក៖ ប៉ុន្តែបងធ្លាប់គិតថាបងចង់ធ្វើជា គ្រូពេទ្យ រឺគ្រូបង្រៀន រឺប៉ូលីស រឺជាទាហ៊ានអីទេបង?

ខ៖ ខ្ញុំដល់ចឹងខ្ញុំដូចអត់មានព្រោះអីទោះបីខ្ញុំស្រម៉ៃក៏ខ្ញុំទៅអត់រួចដែរ ព្រោះអីខ្ញុំបានតែប៉ុណ្ណឹងអែង

ក៖ ប៉ុន្តែបងធ្លាប់គិតថាស្រម៉ៃថាចង់ធ្វើជាអ្នកលក់?

ខ៖ ចង់ពីដំបូងខ្ញុំចង់ថាមានជាផ្ទះមួយ
ហើយយើងមានគ្រួសារហើយយើងលក់ដូរអីតិចតួចអីចឹងដែរហាស
ដូចថាអោយប្រពន្ធលក់ដូរនៅផ្ទះតិចតួចទៅរួចអោយយើងទៅធ្វើការចឹងទៅណា
ដើម្បីជួយគ្នាចិញ្ចឹមជីវភាពគ្រួសាររបស់យើង

ក៖
ចុះបើចង់អោយបងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗតើបងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរបង?

ខ៖ បាទខ្ញុំចង់និយាយថាកូនចៅជំនាន់ក្រោយពេលដែរគាត់ធំដឹងក្ដីហើយ
អោយគាត់ខំរៀនសូត្រកុំអោយដូចខ្ញុំ ខំរៀនសូត្រកុំភ្លើតភ្លើន ខំរកចំនេះវិជ្ជា
ដើម្បីរកការងារធំៗរកលុយស្រួល ដូចខ្ញុំនឹងក្រដោះស្រាយជីវភាពអត់រួច

ក៖ ចុះបងមានធ្លាប់គិតថាចង់អោយលក្ខណះថា
កូនចៅដើម្បីសំរេចគោលបំណងដែរបងបានគិតពីមុនទេបង?

ខ៖ បាទខ្ញុំធ្លាបគិតថាខ្ញុំមានកូនមួយដែរនឹងកូនស្រី
បណ្ដុះបណ្ដាលអោយគាត់ធំឡើងអោយខំរៀនមានចំនេះវិជ្ជាដើម្បីអោយគាត់ធ្វើជាគ្រូពេទ្យម្នាក់

ក៖ បាទធម្មតាបងមានគោលបំណងប៉ុន្តែបងមិនទាន់សំរេចគោលបំណងរបស់បង
ចឹងបងចង់អោយកូនរបស់បងសំរេចនៅគោលបំណងរបស់បងមែនទេបង?

ខ៖ បាទត្រូវហើយ

ក៖ បាទចឹងមានអីផ្សេងទៀតអត់បង?

ខ៖ មានតែប៉ុណ្ណឹងអែង

ក៖ អូបាទចឹងជាចុងក្រោយអរគុណច្រើនបងដែរបានពិភាក្សាជាមួយខ្ញុំ
ហើយនឹងផ្ដល់ពេលវេលាដែរបានចំណាយពេលវេលាដែរបានអោយខ្ញុំបានសំភាសន៍បងមួយនឹងហាសបង
ចឹងនៅពេលដែរខ្ញុំបានសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងដើម្បីអោយកូនចៅក្រោយៗរបស់បងបានស្គាល់ពីប្រវត្តិរបស់បងនឹងឪពុកម្ដាយជីដូនជីតារបស់បងដែរបងបានរៀបរាប់មកពីខាងលើមិញចឹងហាសបង ជាចុងក្រោយខ្ញុំអរគុណច្រើនបង៕៕៕